ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៥៩ /០០៣ / ២០០៣

ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៣

**សេចក្តីសំរេច**

លេខ : ០៥១ /០០២/ ២០០៣ កបធ.ច

ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញមាត្រា ៥០ថ្មី មាត្រា៥៤ថ្មី និងមាត្រា ៦២ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**ក្រោយពីបានស្តាប់សេចក្តីរាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោក **ឈី រី** តំណាងឱ្យឈ្មោះ **ពៅ សោភ័ណ្ឌ** មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់
- យល់ឃើញថា ក្រុមប្រឹក្សាធម្មនុញ្ញបានទទួលពាក្យបណ្តឹងក្នុងកាលបរិច្ឆេទត្រឹមត្រូវតាមការកំណត់នៃច្បាប់
- យល់ឃើញថា ក្រុមប្រឹក្សាជំនុំជម្រះបានចោទសួរភាគីទាំងពីរ ព្រមទាំងសាក្សីបានសព្វគ្រប់ហើយ
- យល់ឃើញថា សាក្សីឈ្មោះ **ឆន់ ម៉ន** និងឈ្មោះ **ឯក សេងា** ពិតជាស្គាល់មនុស្សដែលមានឈ្មោះថា **ពៅ សោភ័ណ្ឌ** ពិតមែន
- យល់ឃើញថា ឈ្មោះ ពៅ សោភ័ណ្ឌ ពុំមានឯកសារអ្វីមួយបញ្ជាក់ថាមានសញ្ជាតិខ្មែរ តាមមាត្រា ៥០ថ្មី និងមាត្រា ៥៤ថ្មី នៃព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ប៉ុន្តែនៅមុខក្រុមប្រឹក្សាជំនុំ

ជម្រះសាធារណៈនាថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០០៣ នាង ពៅ **សោភ័ណ្ឌ** បានបញ្ជាក់ជាច្រើនដងថា នាងមានប័ណ្ណបោះឆ្នោតឆ្នាំ១៩៩៨ និងឆ្នាំ២០០២

-យល់ឃើញថា កាលបរិច្ឆេទបញ្ឈប់ការចុះឈ្មោះបោះឆ្នោតមិនទាន់ហួសពេលនៅឡើយ ។

**ហេតុដូចេ្នះ**

**សំរេចចំពោះមុខគូភាគី**

**មាត្រា ១ :** ទទួលពាក្យបណ្តឹងតវ៉ារបស់លោក **ឈី វី** តំណាងឱ្យឈ្មោះ ពៅ **សោភ័ណ្ឌ** ចុះថ្ងៃទី៤ ខែ កុម្ភៈ ឆ្នាំ២០០៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

**មាត្រា ២ :** បដិសេធសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៣ លើសាក្សី និង តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដដែលលើឯកសារបញ្ជាក់ពីសញ្ជាតិខ្មែរ ។ ប៉ុន្តែបើក្នុងករណីនាង ពៅ **សោភ័ណ្ឌ** បង្ហាញប័ណ្ណបោះឆ្នោតដល់ក្រុមប្រឹក្សាសង្កាត់បឹងសាឡាង មុនពេលផុតកំណត់ការចុះឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៣នោះ នាង ពៅ **សោភ័ណ្ឌ** ត្រូវតែបានចុះឈ្មោះបោះឆ្នោត ។

**មាត្រា ៣ :** សេចក្តីសំរេចនេះប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៣

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន